Australian Government
Department of Social Services

# ការជួញដូរមនុស្ស និងទាសភាព

## ការជួញដូរមនុស្ស និងទាសភាព គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្នុងប្រទេសអូស្ត្រាលី។

ការជួញដូរមនុស្ស និងទាសភាព គឺជាបទល្មើសប្រឆាំងនឹងច្បាប់។

ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ អាចជាប់ពន្ធនាគារ ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

> ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។
>
> ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។
>
> ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទទៅលេខ **131 450**។

## នៅក្នុងស្ថានភាពបែបណាក៏ដោយ រដ្ឋាភិបាលអូស្ត្រាលីមិនអត់ឱនចំពោះការជួញដូរមនុស្ស ឬទាសភាពសម័យថ្មីឡើយ។

ការជួញដូរមនុស្ស និងទាសភាព កើតមានឡើងនៅពេលមនុស្សត្រូវបានគេបង្ខំឱ្យស្ថិតនៅក្នុងស្ថានភាពដែលគេអាចកេងប្រវ័ញ្ចសម្រាប់ការចំណេញរបស់អ្នកដទៃ។ វាអាចកើតឡើងចំពោះបុរស ស្ត្រី និងកុមារ។ ការជួញដូរមនុស្ស និងទាសភាពអាចមានដូចជា៖

- ទាសភាព ភាពត្រូវគេជិះជាន់ ឬពលកម្មដោយបង្ខំនៅក្នុងឧស្សាហកម្មនានា ដូចជាបដិសណ្ឋារកិច្ច សំណង់ ព្រៃឈើ រ៉ែ ឬកសិកម្ម ក៏ដូចជាទំនាក់ទំនងជិតស្និទ្ធផងដែរ
- ទាសភាពបំណុល
- ការកេងប្រវ័ញ្ចផ្លូវភេទ
- អាពាហ៍ពិពាហ៍ដោយបង្ខំ ឬ
- ការជួញដូរក្នុងគោលបំណងដើម្បីវះកាត់យកសរីរាង្គ។

## ការជួញដូរមនុស្ស និងទាសភាព គឺជាឧក្រិដ្ឋកម្មលាក់កំបាំង។

ការជួញដូរមនុស្ស និងទាសភាព គឺជាឧក្រិដ្ឋកម្មដែលអាចពិបាករកឃើញ។ មនុស្សអាចនឹងមិនស្វែងរកជំនួយដោយសារពួកគេភ័យខ្លាចទទួលការសងសឹកពីអ្នកកេងប្រវ័ញ្ចរបស់ពួកគេ ឬបាត់បង់ស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។

សញ្ញាទាំងឡាយចង្អុលបង្ហាញថា បុគ្គលម្នាក់កំពុងត្រូវបានគេជួញដូរអាចរួមមាន ដែលបុគ្គលម្នាក់៖

- ត្រូវបានគេប្រើអំណាចបង្ខំ គំរាមកំហែង ឬបង្ខំឱ្យធ្វើការ។
- ដាក់ឱ្យធ្វើការងារក្នុងស្ថានភាពមិនល្អ។
- មិនបានទទួលប្រាក់ការងារ ឬហាក់ដូចជាកំពុងសងបំណុលយ៉ាងច្រើនដល់និយោជក ឬភាគីទីបីរបស់ពួកគេ ឬ
- ត្រូវបានភាគីទីបីកាន់កាប់លិខិតឆ្លងដែន ឬឯកសារផ្ទាល់ខ្លួនផ្សេងទៀត ហើយមិនមានលទ្ធភាពទទួលបានឯកសារទាំងនេះ តាមដែលខ្លួនចង់បាន។

## តើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ឬ?

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ កំពុងស្ថិតក្នុង ឬប្រឈមនឹងការជួញដូរមនុស្ស និងទាសភាព អ្នកអាចទាក់ទង**ប៉ូលីសសហព័ន្ធអូស្ត្រាលី (Australian Federal Police) (AFP)** តាមទូរស័ព្ទលេខ **131 237** (131AFP) ឬចូលទៅកាន់វិបសាយរបស់ AFP នៅត្រង់ **www.afp.gov.au** ដើម្បីទទួលបានជំនួយ។ AFP អាចរក្សាសុវត្ថិភាពរបស់អ្នក ផ្តល់ដំបូន្មាន និងបញ្ជូនអ្នកទៅកាន់សេវាកម្មផ្សេងៗទៀតសម្រាប់ការគាំទ្រ ដូចជាទីកន្លែងស្នាក់នៅ ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្តល់ប្រឹក្សា និងប្រឹក្សាយោបល់ផ្នែកច្បាប់ និងអន្តោប្រវេសន៍។

**កម្មវិធីការគាំទ្រសម្រាប់មនុស្សដែលត្រូវបានគេជួញដូរ** (**Support for Trafficked People Program**) ត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាល និងចាត់ចែងដោយអង្គការកាកបាទក្រហមអូស្ត្រាលី (Australian Red Cross) ដើម្បីផ្តល់ជំនួយដល់ប្រជាជនដែលជាជនរងគ្រោះនៃការជួញដូរមនុស្ស ឬទាសភាព។

## មានសេវាផ្សេងៗទៀតក្នុងប្រទេសអូស្ត្រាលីដែលអាចជួយបាន។

**1800RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្តល់ព័ត៌មាន និងប្រឹក្សាតាមអ៊ីនធើណិត និងទូរស័ព្ទដោយសម្ងាត់ ហើយឥតគិតថ្លៃ។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

សូមទូរស័ព្ទទៅលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ **1800RESPECT** នៅត្រង់ **www.1800RESPECT.org.au**។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅ **Translating and Interpreting Service** (TIS) ដោយឥតគិតថ្លៃតាមលេខ **131 450**។ TIS  អាចជួយអ្នកឱ្យស្វែងរកសេវាផ្សេងៗទៀតបាន ក៏ប៉ុន្តែ TIS  មិនផ្តល់ការប្រឹក្សាទេ។ គ្រប់ការហៅទូរស័ព្ទទាំងអស់គឺឥតគិតថ្លៃ និងសម្ងាត់។

## ព័ត៌មានបន្ថែមអំពីការជួញដូរមនុស្ស និងទាសភាពក្នុងប្រទេសអូស្ត្រាលី៖

សម្រាប់ព័ត៌មានបន្ថែមអំពី Support for Trafficked People Program សូមចូលទៅកាន់វិបសាយរបស់ក្រសួងសង្គមកិច្ច (Department of Social Services) នៅត្រង់ **www.dss.gov.au** ឬវិបសាយរបស់អង្គការ Australian Red Cross នៅត្រង់ **www.redcross.org.au**។ អ្នកក៏អាចផ្ញើអ៊ីម៉ែលទៅអង្គការ Australian Red Cross តាមអាសយដ្ឋាន **national_stpp@redcross.org.au**។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការជួញដូរមនុស្ស និងទាសភាព សូមចូលទៅកាន់វិបសាយរបស់**ក្រសួងកិច្ចការក្នុងប្រទេស** (**Department of Home Affairs**) នៅត្រង់ **www.homeaffairs.gov.au** ឬវិបសាយរបស់ Australian Federal Police នៅត្រង់ **www.afp.gov.au** ហើយស្វែងរកពាក្យ "ការជួញដូរមនុស្ស" (“human trafficking” )។